# សេចក្តីសង្ខេបអំពីថវិការ
# LCFF សំរាប់មាតាបិតា

ឈ្មោះក្រសួងអប់រំប្រចាំតំបន់ (អិលអ៊ីអេ): Long Beach Unified School District

លេខ CDS: 19-64725

ឆ្នាំសំរាប់ គំរោងការណ៍គ្រប់គ្រង និង ទទួលកិច្ចការខុសត្រូវប្រចាំតំបន់ (អិលខែប): 2019-20

ឈ្មោះបុគ្គលិកប្រចាំក្រសួង អិលអ៊ីអេ សំរាប់ទាក់ទង: Christopher J. Steinhauser, (562) 997-8242, cstein@lbschools.net

ក្រសួងអប់រំ ឌីស្រ្ទីគ ទទួលជំនួយថវិការមកពីប្រភពជាច្រើនចំណែក ដូចជា: ថវិការពី រដ្ឋ ក្រោមរូបមន្ត Local Control Funding Formula (LCFF), ថវិការផ្សេងៗទៀតពី រដ្ឋ, ថវិការនៅតាមតំបន់ និង ថវិការពីរដ្ឋាភិបាលជាតិ ។ ថវិការចេញពី LCFF គឺមានជាថវិការសំរាប់ក្រសួង អិលអ៊ីអេ ប្រើចាត់ចែងទូទៅ រួមទាំងថវិការបន្ថែម ហៅ - "supplemental and concentration" grants - សំរាប់ប្រើជួយសិស្ស ដែលត្រូវការជំនួយច្រើន ស្របតាមចំនួនចុះឈ្មោះពីសិស្សគេជ្រើសចិញ្ចឹម សិស្សរៀនភាសា អង់គ្លេស និង សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ ។

### សេចក្តីសង្ខេបអំពីជំនួយថវិការសំរាប់ឆ្នាំ អិលខែប 2019-20




តារាងនេះបង្ហាញអំពីចំនួនថវិការទាំងអស់សំរាប់ប្រើការទូទៅ ដែល Long Beach Unified School District សង្ឃឹមនឹងបានទទួលមកពីប្រភពជាច្រើនចំណែកសំរាប់ឆ្នាំសិក្សាខាងមុខ ។

# សេចក្តីសង្ខេបអំពីថវិការ
# LCFF សំរាប់មាតាបិតា

ចំនួនថវិការទាំងអស់តាមការស្មានទុក ដែល Long Beach Unified School Disitrct នឹងបានទទួល គឺ $926,486,112.00 ដែលមានចំនួន $738,061,857.00 បានមកពី Local Control Funding Formula (LCFF) $108,008,761.00 បានមកពីប្រភពផ្សេងៗពី រដ្ឋ $20,396,709.00 បានមកពីប្រភពនៅតាមតំបន់ និង $60,018,785.00 បានមកពីរដ្ឋាភិបាលជាតិ ។ ក្នុង $738,061,857.00 បានមកពី LCFF គឺមាន $124,306,579.00 ត្រូវបានទទួលដោយសំអាងលើចំនួនសិស្សចុះឈ្មោះ ដែលជាសិស្សត្រូវការជំនួយច្រើន ដូចជាៈ សិស្សគេជ្រើសចិញ្ចឹម សិស្សរៀនភាសា អង់គ្លេស និង សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ ។

LCFF ផ្តល់សិទ្ធិទៅកាន់ក្រសួងអប់រំ ឪស្រ្ទីគ អំពីការងាយបត់បែនចំណាយថវិការ ដោយទាមទារមកវិញអំពីការសុំអោយក្រសួងអប់រំ ឪស្រ្ទីគ បំពេញកិច្ចការជាមួយ មាតាបិតា គ្រូបង្រៀន សិស្ស និង សហគមន៍ ដើម្បីរៀបចំជា គំរោងការណ៍គ្រប់គ្រង និង ទទួលកិច្ចការខុសត្រូវប្រចាំតំបន់ (អ៊ិលខែប) សំរាប់បង្ហាញមធ្យោបាយចាត់ចែងប្រើជំនួយថវិការទាំងអស់នោះជួយសិស្ស ។




តារាងនេះផ្តល់សេចក្តីសង្ខេបអំពីចំនួនថវិការ ដែល Long Beach Unified School District នឹងចំណាយសំរាប់ឆ្នាំសិក្សា 2019-20 ។ វាបង្ហាញអំពីចំនួនទាំងអស់ ដែលប្រើទាក់ទងការចាត់ចែងកិច្ចការ និង ជំនួយផ្សេងៗនៅក្នុង អ៊ិលខែប ។

Long Beach Unified School District នឹងចំណាយ $930,290,803.00 សំរាប់ឆ្នាំសិក្សា 2019-20 ។ ក្នុងចំនួន $763,213,171.00 គឺប្រើទាក់ទងការចាត់ចែងកិច្ចការ និង ជំនួយផ្សេងៗនៅក្នុង អ៊ិលខែប និង $167,077,632.00 ដែលគ្មានអ្វីទាក់ទងនៅក្នុង អ៊ិលខែប ។ ការចំណាយថវិការ ដែលមិនរាប់បញ្ចូលនៅក្នុង អ៊ិលខែប គឺនឹងយកប្រើសំរាប់ដូចតទៅៈ កម្មវិធីផ្តល់អន្តរាគមន៍ផ្នែកសិក្សា និង ទំនាក់ទំនងជាមួយមាតាបិតា (Title I, III, IV) កម្មវិធីហ្វឹកហ្វឺនសំរាប់បុគ្គលិក (Title II) ការបង្កើនឱកាសរៀន ក្រៅពីម៉ោងរៀនធម្មតា (After School Education and Safety) ការចែកផ្តល់ជំនួយកាន់តែច្រើនទៅកាន់សិស្សត្រូវការច្រើនជាងគេ (Special Education, Migrant Education, Indian Education, McKinney-Vento Homeless Assistance /ល/) កម្មវិធីបង្ហាត់សិស្សធ្វើការងារផ្ទាល់ដៃ (Career Technical Education) និង កម្មវិធីផ្សេងទៀតជាបន្ថែមមកពីរដ្ឋ រដ្ឋាភិបាលជាតិ និង អង្គការប្រចាំតំបន់សំរាប់ជួយសិស្ស ។ កម្មវិធីទាំងអស់នេះត្រូវបានរៀបចំតាមគោលច្បាប់ កម្មវិធីបង្ហាត់ដ៏ខ្លឹមសារ និង ស្របតាមការតំរូវផ្សេងៗ ។

**<u>បង្កើន ឬ នាំមកភាពលូតលាស់ផ្នែកជំនួយសំរាប់សិស្សត្រូវការជំនួយច្រើននៅក្នុងឆ្នាំសិក្សា 2019-20</u>**

នៅក្នុងឆ្នាំសិក្សា 2019-20 គឺ Long Beach Unified School District ស្មានទុកថា នឹងបានទទួលជំនួយថវិការ $124,306,579.00 ដោយសំអាងលើចំនួនចុះឈ្មោះពីសិស្សគេជ្រើសចិញ្ចឹម សិស្សរៀនភាសា អង់គ្លេស និង សិស្សមកពីក្រុមគ្រួសារមានភាពក្រីក្រ ។ ក្រសួង អ៊ិលអ៊ីអេ ត្រូវបង្ហាញគំរោងការណ៍សំរាប់ចាត់ចែងកិច្ចការ និង ជំនួយផ្សេងៗ ដើម្បីបង្កើន ឬ

# សេចក្តីសង្ខេបអំពីថវិការ
# LCFF សំរាប់មាតាបិតា

### ព័ត៌មានថ្មីៗអំពីការបង្កើន ឬ នាំមកភាពលូតលាស់ផ្នែកជំនួយសំរាប់សិស្សត្រូវការជំនួយច្រើននៅក្នុង (ឆ្នាំ អ៊ុលខែប)




តារាងនេះប្រៀបធៀបអំពីអ្វី ដែល Long Beach Unified School District បានចំណាយថវិការកាលពីឆ្នាំកន្លងមកនៅក្នុង អ៊ុលខែប សំរាប់ចាត់ចែងមកលើកិច្ចការ និង ជំនួយផ្សេងៗ ដែលធ្វើអោយមានការបង្កើន ឬ នាំមកភាពលូតលាស់ផ្នែកជំនួយសំរាប់សិស្សត្រូវការជំនួយច្រើន ជាមួយអ្វីផ្សេង ដែល Long Beach Unified School District ស្មានទុកអំពីការបានចំណាយថវិការសំរាប់ការចាត់ចែងកិច្ចការ និង ជំនួយផ្សេងៗ ដែលធ្វើអោយមានការបង្កើន ឬ នាំមកភាពលូតលាស់សំរាប់សិស្សត្រូវការជំនួយច្រើននៅឆ្នាំនេះ ។

នៅក្នុងឆ្នាំសិក្សា 2018-19 គឺ អ៊ុលខែប នៃ Long Beach Unified School District បានរក្សាទុកថវិការចំនួន $120,331,406.00 សំរាប់ការរៀបចំគំរោងចាត់ចែងមកលើកិច្ចការផ្សេងៗដើម្បីបង្កើន ឬ នាំមកភាពលូតលាស់ផ្នែកជំនួយសំរាប់សិស្សត្រូវការជំនួយច្រើន ។ Long Beach Unified School District ស្មានទុកថា នឹងត្រូវចំណាយ $123,599,974.00 សំរាប់ការបង្កើន ឬ នាំមកភាពលូតលាស់ផ្នែកជំនួយសំរាប់សិស្សត្រូវការជំនួយច្រើនៅក្នុងឆ្នាំសិក្សា 2018-19 ។